ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
...............

ក្រសួងសាធារណការ និង ដឹកជញ្ជូន
អគ្គនាយកដ្ឋានសាធារណការ
នាយកដ្ឋាន ផ្លូវថ្នល់
លេខ : ០15......ផ.ថ

ភ្នំពេញ . ថ្ងៃទី២៦ ខែ ០/ ឆ្នាំ ២០០៤

# សេចក្តីណែនាំ
# ស្តីពីការប្រើប្រាស់ផ្លូវថ្នល់

ដោយពិនិត្យឃើញថា ទោះបីមានគោលនយោបាយ ស្តីពីការគ្រប់គ្រង និង ប្រើប្រាស់ដីធ្លី ច្បាប់ភូមិបាល ឆ្នាំ ២០០១ និង សេចក្តីប្រកាសស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី របស់រាជរដ្ឋាភិបាល ក៏នៅតែមានភាពខ្វះខាតសណ្តាប់ធ្នាប់ និង ភាពទទួលខុសត្រូវលើបញ្ហាប្រើប្រាស់ផ្លូវថ្នល់ ឱ្យបានធានាអាយុកាលយូរអង្វែង និង មានសុវត្ថិភាពចរាចរនោះ នាយកដ្ឋានផ្លូវថ្នល់ សូមធ្វើការណែនាំដូច ខាងក្រោម :

## ១. *ស្តីពីការប្រើប្រាស់ផ្លូវថ្នល់*

- សេចក្តីណែនាំនេះមានវិសាលភាពគ្របដណ្តប់លើអ្នកប្រើប្រាស់ផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អ្នកប្រើប្រាស់ផ្លូវសាធារណៈ ត្រូវគោរពឱ្យបានត្រឹមត្រូវ តាមសេចក្តីណែនាំនេះ ។

**សេចក្តីណែនាំនេះកំណត់និយមន័យដូចខាងក្រោម :**

ក / **ផ្លូវជាតិ :**

- ផ្លូវដែលចំណុចចាប់ផ្តើមពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់ទីរួមខេត្ត
- ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ទីរួមខេត្ត
- ផ្លូវបំបែកចេញពីផ្លូវជាតិ ឆ្ពោះទៅភ្ជាប់នឹងផ្លូវជាតិ
- ផ្លូវផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

*. ***ប្រភេទផ្លូវជាតិ :***

ផ្លូវជាតិបែងចែកជា ២ កំរិត :

- ផ្លូវជាតិកំរិត 1 : ជាផ្លូវជាតិដែលមានលេខ ១ ខ្ទង់
- ផ្លូវជាតិកំរិត 2 : ជាផ្លូវជាតិដែលមានលេខ ២ ខ្ទង់

ខ / **ផ្លូវខេត្ត :**

1- ផ្លូវខេត្តជាផ្លូវដែលចេញពីខេត្ត ឆ្ពោះទៅកាន់ទីរួមស្រុក ។
2- ផ្លូវបែកចេញពីផ្លូវជាតិ ទៅផ្លូវខេត្ត ។
3- ផ្លូវបំបែកពីផ្លូវខេត្ត ឆ្ពោះទៅស្រុកក្នុងករណីចំនួនចរាចរមធ្យមប្រចាំថ្ងៃ ADT ធំជាងឬស្មើនឹង 50 ។
4- ផ្លូវបំបែកចេញពីផ្លូវខេត្ត ឆ្ពោះទៅផ្លូវខេត្ត ។
5- ផ្លូវជនបទ ក្នុងករណី ចំនួនមធ្យោបាយចរាចរមធ្យមប្រចាំថ្ងៃ ធំជាង ឬស្មើ 50 ( ADT) ។

6- ផ្លូវផ្សេងៗ ទៀត តាមការកំណត់របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

***ប្រភេទលេខផ្លូវខេត្ត :***

ផ្លូវខេត្តមាន ៣ លេខ ឬ ៤លេខ

គ / **ផ្លូវជនបទ :**

1- ផ្លូវដែលចេញពីផ្លូវជាតិ ឆ្ពោះទៅ ឃុំ - ភូមិ

2- ផ្លូវដែលចេញពីផ្លូវខេត្ត ឆ្ពោះទៅ ឃុំ - ភូមិ

3- ផ្លូវដែលចេញពីទីរួមស្រុក ទៅទីរួមស្រុក

4- ផ្លូវចេញពីទីរួមស្រុក ទៅឃុំ

5- ផ្លូវចេញពីឃុំ ទៅឃុំ

6- ផ្លូវចេញពីឃុំ ទៅ ភូមិ

7- ផ្លូវបែកពីភូមិ ទៅ ភូមិ

*ពាក្យថា : " **ផ្លូវសាធារណៈ** " គឺជាផ្លូវសំរាប់បើកឱ្យធ្វើចរាចរទូទៅ ជាសាធារណៈ ។

*ពាក្យថា : " **ផ្លូវថ្នល់** " ហៅកាត់ថា " **ផ្លូវ** " គឺជាទំហំទាំងមូលនៃទ្រូងផ្លូវនិង ចិញ្ចើមផ្លូវ ។

*ពាក្យថា : "**ទ្រូងផ្លូវ**" គឺជាផ្នែកមួយនៃផ្លូវទុកសំរាប់យានជំនិះ គ្រប់ប្រភេទ ធ្វើចរាចរ ។

*ពាក្យថា : "**ជាយផ្លូវ ឬចិញ្ចើមផ្លូវ**" គឺជាផ្នែកសងខាង នៃទ្រូងផ្លូវ ។

*ពាក្យថា : "**ដីចំណីផ្លូវ**" គឺជាផ្ទៃដី គិតចាប់ពីអក្សផ្លូវ ដែលមានចំងាយពីអក្សផ្លូវទៅតាមប្រភេទផ្លូវ ។

-**ផ្លូវជាតិមានលេខ មួយខ្ទង់ :**

- ផ្លូវជាតិលេខ: ២, ៣ , ៦ , ៧ , ៨ ដីចំណីផ្លូវមានចំងាយ ២៥ ម៉ែត្រ ពីសងខាងអក្សផ្លូវ ។
- ផ្លូវជាតិលេខ: ១ , ៤ , ៥ ដីចំណីផ្លូវមានចំងាយ ៣០ ម៉ែត្រពីសងខាងអក្សផ្លូវ ។

-**ផ្លូវជាតិមានលេខ ពីរខ្ទង់ :**

ឧទាហរណ៍ : ផ្លូវជាតិលេខ ១១ , ១២ , ៦៤ , ៧៨ ដីចំណីផ្លូវមានចំងាយ ២៥ ម៉ែត្រ ពីសងខាង អ័ក្សផ្លូវ ។

-**ផ្លូវខេត្ត**

- ដីចំណីផ្លូវ មានចំងាយ ២០ ម៉ែត្រ ពីសងខាង អក្សផ្លូវ ។

-**ផ្លូវលំ**

- ដីចំណីផ្លូវ មានចំងាយ ២០ ម៉ែត្រ ពីសងខាង អក្សផ្លូវ ។

-**ផ្លូវទីរួមខេត្ត -ក្រុង -ទីប្រជុំជន**

- ផ្លូវមានទទឹង ៥ម៉ែត្រ ដល់ ១១ម៉ែត្រ ដីចំណីផ្លូវ គិតពីចិញ្ចើមប្រវែង ៦ ម ។
- ផ្លូវមានទទឹង ១២ម៉ែត្រ ដល់ ១៨ម៉ែត្រ ដីចំណីផ្លូវ គិតពីចិញ្ចើម ប្រវែង ៨ម ។

***២_ សំពីការប្រើប្រាស់ផ្លូវខ្នង_-***

ក-យានយន្តទាំងឡាយដែលមានកង់ច្រវ៉ាក់ មិនអនុញ្ញាតិអោយបើកបរលើទ្រូងផ្លូវឡើយ យានយន្តទាំងនោះ ត្រូវដឹកជញ្ជូនដោយរថយន្តសណ្តោង ។

ខ-យានយន្តទាំងឡាយណាដែលកំពុងធ្វើចរាចរ ហើយមានការខូចខាតបន្ទាន់មិនអនុញ្ញាតិអោយឈប់ចត នៅកណ្តាលទ្រូងផ្លូវទេ ត្រូវអូសមកជាយផ្លូវដើម្បីធ្វើការជួសជុលជាមួយគ្នានោះ គេត្រូវដាក់ សញ្ញាសំគាល់ពេលថ្ងៃ និង ដាក់ភ្លើងបំភ្លឺនៅពេលយប់ ដោយមានចំងាយ ពីយានយន្ត ៣០ម៉ែត្រនៅ ខាងមុខយានយន្ត និងខាងក្រោយយានយន្ត។

គ-ការប្រើប្រាស់ដូយដោយផ្ទាល់ទៅលើផ្ទៃផ្លូវថ្នល់ត្រូវហាមឃាត់ជាច់ខាត ។ គេត្រូវប្រើកំណាល់ឈើ ឬ កំណាល់ផ្សេងៗ ទៀត ដែលមានទំហំធំជាងឬស្មើ 0,0៩ម$^{២}$ ។

ឃ-ក្នុងគ្រប់ករណីការផ្ទុកឈើហ៊ុប ឬ វត្ថុផ្សេងៗ ទៀតដែលមានបណ្តោយវែងជាងទ្រុងយានយន្តនោះមិនត្រូវឱ្យលូតហួសពីគែមខាងមុខយានយន្ត និង មិនត្រូវអោយហួសពីគែមទ្រុង ខាងក្រោយនៃយានយន្តចំងាយ១ម៉ែត្រ ឬ ធ្លាក់អូសដីឡើយ ។

ង-ហាមដឹកដី ដីខ្សាច់ គ្រួស ថ្ម សំរាមតាមដងផ្លូវដោយគ្មានគំរបការពារ។ ការដឹកជញ្ជូនទាំងឡាយណាដែលនាំឱ្យខូចគែមទ្រូងផ្លូវ ត្រូវសុំសេចក្តីអនុញ្ញាតិពីស្ថាប័នជំនាញក្រសួងសាធារណការ និងដឹកជញ្ជូនសិន ។

ច-ហាមឈប់ ឬ ចតរថយន្តដឹកជញ្ជូន បន្តកន្ទុយគ្នា ។ ក្នុងករណីចាំបាច់អាចឈប់ ឬ ចតបានដោយ ត្រូវមានចំងាយពីរថយន្តមួយ ទៅ រថយន្តមួយចំនួនយ៉ាងតិច ៤ម៉ែត្រ ។

ឆ-ហាមផ្ទុកទំនិញនៅលើយានយន្ត មិនត្រូវអោយលើសទំងន់សរុបអតិបរមារបស់យានយន្ត ដែលកំណត់ដោយរោងចក្រផលិតយានយន្តឡើយ និង ឱ្យស្របទៅនឹងអនុក្រិត្យលេខ ៨៣ អនក្រ .បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៩៩ ។

ជ-ហាមចោះ ឬ កាត់ផ្តាច់ផ្លូវថ្នល់ ដើម្បីបង្កប់ប្រពន្ធ័លូ ប្រពន្ធ័ខ្សែអគ្គីសនី ឬ ប្រពន្ធ័ខ្សែ ទូរស័ព្ទប្រព័ន្ធ ទឹកស្អាត ។ល។ ដោយគ្មានការអនុញ្ញាតិ ពីក្រសួងសាធារណការ និង ដឹកជញ្ជូន ។

ឈ-ហាមហាលរបស់របរ លើទ្រូងផ្លូវ ។

ញ-ហាមចាក់ទឹកលើទ្រូងផ្លូវ ។

ដ-ក្នុងករណីមានប្រេងឥន្ធនៈ ហៀរហូរ លើទ្រូងផ្លូវកៅស៊ូ ត្រូវធ្វើការលាងសំអាតជាបន្ទាន់ ។

## ការប្រើប្រាស់ជាយផ្លូវ

- ហាមចាក់ដីលើកកំពស់ជាយផ្លូវ ក្នុងករណីចាំបាច់ត្រូវពិគ្រោះជាមួយស្ថាប័នក្រសួងសាធារណការ ។
- ហាមចាក់ដី សំរាម ទៅក្នុងប្រឡាយ និង រណ្តៅលូបង្ហូរទឹក ។
- ហាមសង់តូប តាំងទីលំនៅ ដាក់មុខទំនិញលើជាយផ្លូវ លើប្រឡាយ និងលើលូបង្ហូរទឹក ។
- ហាមដាំ ដំណាំ ដើមឈើ ឬ ហាលវត្ថុផ្សេងៗ លើជាយផ្លូវ ។
- ហាមចោះ ឬ កាត់ផ្តាច់ជាយផ្លូវ ដើម្បីកប់បំពង់លូ ប្រពន្ធ័ខ្សែអគ្គីសនី ប្រពន្ធ័ខ្សែទូរសព្ទ័ ។ល។ដោយគ្មានការអនុញ្ញាតិពី ក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- ហាមចងសត្វពាហនៈ តាមជាយផ្លូវ ។
- ហាមដឹកដីតាមជាយផ្លូវ ។

ប្រើប្រាស់ដីចំណីផ្លូវ-

- ដីចំណីផ្លូវជាកម្មសិទ្ធ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

- ហាមធ្វើរបងនៅលើដីចំណីផ្លូវ

- ហាមសង់លំនៅដ្ឋានលើដីចំណីផ្លូវ

- ហាមទប់ទឹកដែលហូរចេញពីទ្រូងផ្លូវ

- ហាមជីករាំងព្រួលតាមប្រឡាយ លូ ស្ពាន ដែលបណ្តាលឱ្យរាំងស្ទះចរន្តទឹក

៥-ទិធានការអនុវត្តន៍-

រាល់ការងារទាំងឡាយណាដែលពាក់ពន្ធ័នឹងការងារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទោះជាប្រើប្រាស់ប្រភពថវិកាណាក៏ដោយ ការងារបច្ចេកទេសត្រូវតែឆ្លងស្ថាប័នជំនាញ (មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្ត-ក្រុង ក្រសួង) ជាដាច់ខាត ហើយស្ថាប័ជំនាញជំនូសមុខក្រសួងធ្វើការគ្រប់គ្រងឱ្យបានហ្មត់ចត់ និងមធ្យ័តបំផុត។

ក្រោយពេលទទួលបានសេចក្តីណែនាំនេះ សូមលោកប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូនគ្រប់ខេត្តក្រុង ចាត់វិធានការអនុវត្តន៍ឱ្យបានប្រសិទ្ធិភាពខ្ពស់ ។ប្រសិនបើមានភាពធ្វេសប្រហែសគ្មានភាពទទួលខុសត្រូវ នោះនាយកដ្ឋាន និង រាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងដើម្បីដាក់ពិន័យ ឬ បន្ទោសតាមច្បាប់វិន័យ របស់ក្រសួង ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

នាយក នាយកដ្ឋាន ផ្លូវថ្នល់

លឹម-ស៊ីដេនីន

ចំលងជូន

- ឯកឧត្តមរដ្ឋលេខាធិការ
- ឯកឧត្តមអនុរដ្ឋលេខាធិការ
- ឯកឧត្តមអគ្គនាយក សាធារណការ
- ឯកឧត្តមអគ្គនាយករង សាធារណការ
- ឯកឧត្តមអគ្គនាយក រដ្ឋបាល
- ឯកឧត្តមអភិបាលខេត្ត ក្រុង
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

---

លេខ..០៤២.សកឋជ.កច

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

កំពង់ចាម ថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ 2004

ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន

ខេត្តកំពង់ចាម

ស៊ុខ-ស៊្រុន

ចម្លងជូន

- លោកអភិបាលស្រុកគ្រប់ស្រុក
  " ដើម្បីជ្រាបជាពត៌មាន "
- ការិយាល័យសាធារណការស្រុកគ្រប់ស្រុក
  " ដើម្បីសហការអនុវត្ត "
- ឯកសារ -